# ចំណេះចំណានខាងគោលលទ្ធិនៃ ព្រះគម្ពីរសញ្ញាថ្មី ៖ ការវាយតម្លៃទី ២

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

## សេចក្តីយោងចំណេះចំណានខាងគោលលទ្ធិ

សម្រាប់សំណួរទី ១–៣ សូមសរសេរអក្សរនៃសេចក្តីយោងដែលត្រូវគ្នាក្នុងចន្លោះទទេនៅជាប់នឹងឃ្លានីមួយៗ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

១. ______ « សេចក្តីជំនឿ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់ » ។

២. ______ « សម្រាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ » ។

៣. ______ « ក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹងអាស្រ័យដល់បុរសដែរ » ។

ក. កូរិនថូស ទី១ ១១:១១

ខ. អេភេសូរ ១:១០

គ. ធីម៉ូថេ ទី២ ៣:១៥–១៧

ឃ. យ៉ាកុប ២:១៧–១៨

ង. វិវរណៈ ២០:១២

## ឃ្លាបទគម្ពីរគន្លឹះ

សម្រាប់សំណួរទី ៤–៦ សូមបំពេញពាក្យដែលបាត់ក្នុងឃ្លាបទគម្ពីរគន្លឹះចំណេះ ចំណានខាងគោលលទ្ធិ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

៤. « ______________អ្នករាល់គ្នាជា ______________នៃ________________» ។ ( កូរិនថូស ទី១ ៦:១៩–២០ ) ។

៥. សាសនាចក្រត្រូវបាន « ស្អាងឡើងលើ ______________ នៃ ______________និងពួកហោរា ហើយ ______________ ______________ នោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក » ( អេភេសូរ ២:១៩–២០ ) ។

៦. « ថ្ងៃនៃព្រះអម្ចាស់ … មិន ______________ ឡើយ ទាល់តែមាន ______________ មកជាមុន ______________» ( ថែស្សាឡូនីច ទី២ ២:១–៣ ) ។

អ្នកអាចប្រើប្រាស់ព្រះគម្ពីររបស់អ្នកសម្រាប់ការវាយតម្លៃដែលនៅសល់ ។

សម្រាប់សំណួរទី ៧–៩ សូមរកមើលវគ្គបទគម្ពីរចំណេះ ចំណានខាងគោលលទ្ធិមួយ ឬច្រើនដែលអាចជួយនរណាម្នាក់ក្នុងស្ថានភាពដូចខាងក្រោម ។

| | |
|---|---|
| ៧. មនុស្ស ជា ទីស្រឡាញ់ នៃ មិត្ត របស់ អ្នក បានទទួល មរណភាព ថ្មីៗ នេះ ។ មិត្តរបស់អ្នកមានសំណួរជាច្រើនអំពីអ្វីដែលកើតឡើងចំពោះយើងបន្ទាប់ពីការស្លាប់ ។ | |
| ៨. បងប្រុស របស់ អ្នក ហាក់ ដូចជា ពិបាក ហើយ កំពុង សួរថា តើ ព្រះ ពិតជា ដឹង អំពី គាត់ ឬ អត់ ។ | |
| ៩. អ្នក ដឹកនាំ សាសនា ចក្រ សុំឲ្យអ្នក ផ្តល់ ដំបូន្មានដល់មិត្តភក្តិរបស់អ្នកនៅក្នុងមេរៀន សាលាថ្ងៃអាទិត្យ នាពេល ខាងមុខ អំពី របៀប ដែល ពួកគេ អាច រក្សា ភាពស្មោះត្រង់ នៅពេល ប្រឈមមុខនឹង គំនិត មិនពិត និង ការល្បួង ។ | |

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *New Testament Doctrinal Mastery: Assessment 2* ។
Cambodian ។ PD60012661 258. Printed in the United States of America.

នៅក្នុងសំណួរទី ១០–១១ សូមបង្ហាញចំណេះដឹងរបស់អ្នកអំពីសមត្ថភាពក្នុងការប្រើប្រាស់ គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ ។

១០. តើ អ្នក នឹងពន្យល់ពីគោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណបីខាងក្រោមដល់បុគ្គលម្នាក់ ដែលមិនស្គាល់គោលការណ៍ទាំងនោះដោយរបៀបណា ?

ក. ធ្វើសកម្មភាពដោយសេចក្តីជំនឿ

ខ. ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យដ៏នៅអស់កល្បជានិច្ច

គ. ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលបានតែងតាំងដ៏ទេវភាព

១១. អ្នក មាន មិត្តម្នាក់ ដែល ហៀប នឹង បញ្ចប់ ការសិក្សា នៅ វិទ្យាល័យ ហើយ មាន ការភ័យខ្លាចចំពោះ ការសម្រេចចិត្ត សំខាន់ៗ ដែល នាង នឹង ធ្វើ នៅក្នុង ជីវិត របស់ នាង ក្នុង រយៈពេល ប៉ុន្មាន ឆ្នាំ ខាងមុខ នេះ ។ សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើរឿងជាក់លាក់អ្វីខ្លះដែលអ្នកនឹងអញ្ជើញនាងឲ្យធ្វើ ដើម្បីធ្វើសកម្មភាពដោយសេចក្តីជំនឿ ?

ខ. តើអ្នកអាចជួយនាងឲ្យមើលឃើញស្ថានភាពរបស់នាងជាមួយនឹងទស្សនវិស័យដ៏នៅអស់កល្បជានិច្ចយ៉ាងដូចម្តេច ?

គ. វគ្គបទគម្ពីរចំណេះ ចំណានខាង គោលលទ្ធិគឺជាឧទាហរណ៍នៃប្រភពដែលបានតែងតាំងដ៏ទេវភាព ។ តើវគ្គ បទគម្ពីរចំណេះ ចំណានខាងគោលលទ្ធិ ( នានា ) អ្វីខ្លះ ដែលអ្នកអាចចែកចាយជាមួយមិត្តរបស់អ្នក ? ហេតុអ្វី ?

១២. ក្នុងចំណោមវគ្គ បទគម្ពីរចំណេះ ចំណានខាងគោលលទ្ធិទាំង ១៣ ដែលអ្នកបានសិក្សារួចកន្លងមក នៅក្នុងឆមាសនេះ តើវគ្គ បទគម្ពីរណាមួយដែលជះឥទ្ធិពលលើអ្នកច្រើនបំផុត ហើយហេតុអ្វី ? តើវគ្គ បទគម្ពីរនេះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *New Testament Doctrinal Mastery: Assessment 2* ។
Cambodian ។ PD60012661 258. Printed in the United States of America.